# រឿង
# ទីណូនិង ស្បែកជើង



ឆ្នាំ ២០១០

អ្នកនិពន្ធ : លោកស្រី តឹក ស៊ីផុន
: លោកស្រី ឃឹម ចាន់ស្រី
អ្នករៀបរៀង : លោកស្រី ហួត សេយ៉ោន

វិចិត្រករ : លោក ឯម សត្យា

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពីក្រសួងអប់រំ សេចក្តីសម្រេចលេខ ១៣៨ អរ.សសរ.
ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩០ ដើម្បីប្រើប្រាស់នៅតាមសាលារៀនមត្តេយ្យ

គ្រឹះស្ថានបោះពុម្ពផ្សាយអប់រំ

បោះពុម្ពលើកទី១ ចំនួន៥,000ក្បាល
រោងពុម្ពក្រសួងអប់រំ ឆ្នាំ១៩៩១

អំណោយ អ៊ុយនីសេហ្វ
DON DE L'UNICEF

បោះពុម្ពលើកទី២ដោយ : អង្គការគាំពារកុមារខ្មែរ (CYK)

ភ្នំពេញ ខែកក្កដា ឆ្នាំ២០១០

មូលនិធិ : ប្រាក់សន្សំរបស់អ្នកចូលរួមទាំងអស់នៅប្រៃសណីយ៍ជប៉ុនសម្រាប់ជំនួយស្ម័គ្រចិត្តអន្តរជាតិ

ចំនួន : ៥,000ក្បាល

លេខ : CYK N10013

រោងពុម្ព : **J S R C** Printing House



រាល់ថ្ងៃទីណូ  ដើរទៅសាលារៀនជើងទទេ។ ជួនកាលវាដើរទៅមុតជើងនឹងបន្លា ឬ អំបែងកែវ ជាន់ភក់ប្រឡាក់ជើង និងជាប់មេរោគ។



មិត្តទាំងអស់នៅសាលារៀនតែងពន្យល់ឱ្យទីណូរកស្បែកជើងពាក់ ដើម្បីឱ្យមានអនាម័យដូចមិត្តដទៃទៀត។



បងនារីនិយាយៈ

"ទីណូ! ទីណូឯងរកស្បែកជើងពាក់ទៅ។ ទីណូមិនពាក់ស្បែកជើងអញ្ចឹង គ្មានអនាម័យទេ។ ម្យ៉ាងទៀតយើងដើរមករៀនក្ដៅជើងណាស់។



ទីណូសួរនារីៈ "បើគ្មានអនាម័យវាឆ្លងមេរោគឬ បងនារី?"



នារីឆ្លើយ៖ "មែនហើយទីណូ ឆ្លងមេរោគគឺយើងឈឺ បើឈឺ ទីណូឯងខានមករៀនហើយ"។



ទីណូបញ្ញាក់៖ "បងនារីនិយាយត្រូវមែន បងនារីជួយមើលជើងខ្ញុំនែ៎ បន្ទាមុតពីថ្ងៃមុន ឥឡូវហើមមានខ្ទុះ។ អូយឈឺណាស់បងនារីអើយ ខ្ញុំក្ដៅខ្លួនស្ទើញៗផង មេរោគច្បាស់ជាចូលក្នុងខ្លួនខ្ញុំច្រើនហើយមើលទៅ។ ទៅដល់ផ្ទះខ្ញុំសុំឪពុកខ្ញុំឱ្យធ្វើស្បែកជើងឱ្យខ្ញុំមួយគូហើយ។



ទៅដល់ផ្ទះទីណូ សុំឱ្យឪពុកធ្វើស្បែកជើងឱ្យទីណូមួយគូ។ ឪពុកទីណូកាប់ដើមឈើមួយដើម យកមកចោះលុងធ្វើស្បែកជើងឱ្យទីណូ។ ទីណូអង្គុយចាំមើលឪពុកធ្វើស្បែកជើងទាល់តែហើយ។



ទីណូពាក់ស្បែកជើងហើយនិយាយៈ "អស្ចារ្យមែន! ពុកចេះធ្វើស្បែកជើងត្រូវល្មមជើងកូន! កូនសប្បាយចិត្តណាស់ពុក! កូនសន្យាថានឹងថែស្បែកជើងនេះ មិនឱ្យខូច មិនឱ្យដាច់ខ្សែ។ កូនពាក់ដោយប្រុងប្រយ័ត្នមិនឱ្យប្រឡាក់ភក់ទេ។ បើមានប្រឡាក់បន្តិចបន្តួចកូនជូតចេញភ្លាម ហើយកូននឹងខំថែវាដើម្បីពាក់ឱ្យបានយូរ ណ៎ាពុក"។



ឪពុកទីណូឆ្លើយ៖ "ល្អហើយកូន! កូនល្អត្រូវតែថែទាំរបស់ប្រើប្រាស់ដូចនេះណ៎ា ឪពុកសប្បាយចិត្តណាស់"។

ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានអប់រំកុមារតូច

This aid project is supported by all participants in Japan's
Postal Saving for International Voluntary Aid.
**និងអង្គការគាំពារកុមារខ្មែរ** ( CYK )

9789996317040